ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
អគ្គនាយកដ្ឋានការងារ
នាយកដ្ឋានពេទ្យការងារ

# គោលការណ៍ណែនាំ
# ស្តីពី
# សុវត្ថិភាពសារធាតុគីមីនៅកន្លែងធ្វើការ

គាំទ្រដោយៈ មូលនិធិរាជរដ្ឋាភិបាលជប៉ុន តាមរយៈគម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព
និងសុខភាពការងារក្នុងវិស័យសំណង់ នៃអង្គការអន្តរជាតិខាងការងារ
( ILO/Japan OSH Project)

# បុព្វកថា

ការធានា និងលើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរ ពង្រឹងភាពសុខដុមរមនាទំនាក់ទំនងវិជ្ជាជីវៈ ការរក្សា និងបង្កើតការងារទាំងក្នុង និងក្រៅប្រទេស និងធានាការគាំពារសង្គម ឱ្យឆ្លើយតបនឹងតម្រូវការទីផ្សារការងារនៃគម្រោងវិនិយោគថ្មីៗ សំដៅបង្កើតឱកាសការងារកាន់តែច្រើនបង្កើនផលិតភាពប្រកបដោយគុណភាព ជាការរួមចំណែកក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ទន្ទឹមនេះ ការកើនឡើងក្នុងវិស័យពាណិជ្ជកម្ម និងផលិតកម្ម សារធាតុគីមីក៏បានធ្វើឱ្យមានកង្វល់យ៉ាងខ្លាំងអំពីសក្តានុពលនៃហានិភ័យ ដែលកើតឡើងដោយសារធាតុគីមីដែលបាននាំចូល និងប្រើប្រាស់ ហើយសារធាតុគីមីទាំងនោះកំពុងតែបង្កឱ្យមានហានិភ័យ និងគ្រោះថ្នាក់ ក្នុងប្រទេសដែលខ្វះខាតហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រង។

សារធាតុគីមីជាច្រើនពាន់ប្រភេទ ត្រូវបានប្រើប្រាស់ជាសារធាតុផ្សំ និងសារធាតុគីមីថ្មីៗជាច្រើនទៀត បាននាំចូល និងផលិតក្នុងស្រុកដែលមានការប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងឧស្សាកម្ម ព្រមទាំងស្ទើរតែគ្រប់ប្រភេទការងារទាំងអស់នៅកន្លែងធ្វើការ។

ឆ្លើយតបទៅនឹងកង្វល់ខាងលើ កត្តាចាំបាច់ដែលមិនអាចខ្វះបាន គឺត្រូវមានប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងការតាមដានអំពីលំហូរនាំចូល និងការប្រើប្រាស់សារធាតុគីមី ព្រមទាំងធ្វើឱ្យមានភាពប្រាកដច្បាស់អំពីការទទួលព័ត៌មាននៃការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់នៅកន្លែងធ្វើការ សម្រាប់វាយតម្លៃអំពីហានិភ័យ សំដៅឈានឆ្ពោះទៅ

សម្រេចគោលដៅកាត់បន្ថយហានិភ័យ សារធាតុគីមីនៅកន្លែងធ្វើការឱ្យនៅកម្រិតអប្បរមាដើម្បីធានាសុវត្ថិភាពកម្មករនិយោជិត។

សៀវភៅ **គោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមីនៅកន្លែងធ្វើការ** ដែលបានរៀបចំឡើងជាភាសាខ្មែរ និងអមដោយការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការនេះ គឺជាស្នាដៃ និងជាសមិទ្ធផលបានមកពីការខិតខំប្រឹងប្រែងរបស់ក្រសួង ដើម្បីឆ្លើយតបនឹងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ សម្រាប់ជួយដល់វិស័យឯកជន ពិសេសរោងចក្រ សហគ្រាស និងក្រុមហ៊ុនពាក់ព័ន្ធទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនការគ្រប់គ្រងហានិភ័យនៃសារធាតុគីមីនៅកន្លែងធ្វើការ ធានាសុវត្ថិភាពកម្មករនិយោជិត និងអ្នកប្រើប្រាស់សារធាតុគីមី ផលិតផលគីមីទាំងអស់នៅកន្លែងធ្វើការ។

សៀវភៅគោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារស្នូល ក្រោមការដឹកនាំរបស់នាយកដ្ឋានពេទ្យការងារ ដោយអនុលោមតាមសៀវភៅគោលការណ៍ណែនាំរបស់អង្គការអន្តរជាតិខាងការងារ (ILO) និងអង្គការសុខភាពពិភពលោក (WHO) ក្រោមការឧបត្ថម្ភគាំទ្រពីអង្គការអន្តរជាតិខាងការងារ (ILO) និងការផ្តល់ធាតុចូលពីក្រសួង ស្ថាប័ន អង្គការវិជ្ជាជីវៈ និងសមាជិក សមាជិកានៃក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងលើកកម្ពស់ស្តង់សុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ (ILO/Japan OSH Project) ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវអំណរគុណចំពោះអង្គការអន្តរជាតិខាងការងារ (ILO) តាមរយៈគម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា (ILO/ Japan OSH Project) ដែលបានជួយឧបត្ថម្ភគាំទ្រទាំងបច្ចេកទេស និងថវិកា និងក្រុមការងារ ក្នុងការរៀបចំគោលការណ៍នេះឡើង។ សូមថ្លែងអំណរគុណផងដែរដល់សមាជិក សមាជិកានៃក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា ដែលបានផ្តល់ធាតុចូលល្អៗ នៅក្នុងដំណើរការរៀបចំសៀវភៅនេះរហូតបានចប់សព្វគ្រប់។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

# មាតិកា

**១. គោលដៅ** ............................................................ ៧

**២. គោលបំណង និងវិសាលភាព** ............................................................ ៧

២.១. គោលបំណង ............................................................ ៧

២.២. វិសាលភាព ............................................................ ៧

**៣. និយមន័យ** ............................................................ ៨

**៤. ភាគព្វកិច្ច ការទទួលខុសត្រូវ និងភារៈកិច្ច** ............................................................ ១០

៤.១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ............................................................ ១០

៤.២ អង្គការវិជ្ជាជីវៈ ............................................................ ១០

៤.៣ អ្នកផ្គត់ផ្គង់ ............................................................ ១២

៤.៤ អ្នកជំនាញ ឬអ្នកឯកទេសផ្នែកសារធាតុគីមី ............................................................ ១៣

**៥. ការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី** ............................................................ ១៣

៥.១ ការចាត់ថ្នាក់សារធាតុគីមី ............................................................ ១៣

៥.២ លក្ខណៈវិនិច្ឆ័យនៃការចាត់ថ្នាក់សារធាតុគីមី ............................................................ ១៣

៥.៣ ការបិទស្លាកសញ្ញា ........................................ ១៤

**៦. តារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី** ........................................ ១៥

**៧. វិធានការក្នុងការកំណត់ និងគ្រប់គ្រងហានិភ័យ** ........................................ ២២

៧.១. ការកំណត់ និងវាយតម្លៃហានិភ័យ ........................................ ២២

៧.២. វិធានការគ្រប់គ្រងហានិភ័យ ........................................ ២៩

៧.៣. ការរក្សាទុក និងការផ្ទេរសារធាតុគីមី ........................................ ៣០

៧.៤. ការដឹកជញ្ជូន ឬបំលាស់ទី ........................................ ៣២

៧.៥. ការបោះចោលសំណល់សារធាតុគីមី ........................................ ៣២

**៨. វិធានការការពារបុគ្គល** ........................................ ៣៣

៨.១. សម្ភារការពារបុគ្គល ........................................ ៣៣

៨.២. ឧបករណ៍ ឬបរិក្ខារការពារផ្លូវដង្ហើម ........................................ ៣៤

៨.៣. សម្លៀកបំពាក់ការពារ ........................................ ៣៦

៨.៤. ការថែទាំ រក្សាទុក និងត្រួតពិនិត្យ ........................................ ៣៦

**៩. ការឆ្លើយតបនៅគ្រាអាសន្ន** ........................................ ៣៨

៩.១. វិធានការឆ្លើយតបនៅគ្រាអាសន្ន ........................................ ៣៨

៩.២. ការសង្គ្រោះបឋម ........................................................................ ៣៩

**១០. ការបណ្តុះបណ្តាល និងព័ត៌មាន** ............................................. ៤៣

**១១. ការពិនិត្យតាមដាន និងវាយតម្លៃ** ........................................ ៤៤

**១២. ឯកសារយោង** ........................................................................ ៥៤

# ១. គោលដៅ

គោលការណ៍ណែនាំនេះមានគោលដៅកាត់បន្ថយហានិភ័យសារធាតុគីមីនៅកន្លែងធ្វើការ។

វាក្យស័ព្ទ "សារធាតុគីមី" ប្រើនៅក្នុងគោលការណ៍ណែនាំនេះសំដៅដល់ សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់។

# ២. គោលបំណង និងវិសាលភាព

## ២.១. គោលបំណង

- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការចាត់ថ្នាក់ ការដាក់ស្លាកសញ្ញា ការដឹកជញ្ជូន ការទុកដាក់ និងការប្រើប្រាស់សារធាតុគីមី
- ធានាសុវត្ថិភាពកម្មករនិយោជិត និងអ្នកប្រើប្រាស់សារធាតុគីមី ផលិតផលគីមីទាំងអស់នៅកន្លែងធ្វើការ
- ផ្តល់ការបណ្តុះបណ្តាល អប់រំ និងផ្តល់ព័ត៌មាន ឱ្យបានគ្រប់គ្រាន់ទៅដល់កម្មករនិយោជិតនិងអ្នកប្រើប្រាស់សារធាតុគីមី អំពីលក្ខខណ្ឌដែលអាចបង្កគ្រោះថ្នាក់ដោយសារធាតុគីមី
- កាត់បន្ថយហានិភ័យដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ពីឥទ្ធិពលគ្រោះថ្នាក់ដែលអាចបង្កដោយសារធាតុគីមីនៅជុំវិញបរិវេណ និងទីកន្លែងធ្វើការ។

## ២.២. វិសាលភាព

គោលការណ៍ណែនាំនេះ មានវិសាលភាព៖

- អនុវត្តចំពោះនិយោជក និងកម្មករនិយោជិត នៃរោងចក្រ សហគ្រាស ដែលស្ថិតនៅក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ព្រមទាំងសហគ្រាសខ្នាតតូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- គ្របដណ្តប់គ្រប់សារធាតុគីមី លើកលែងតែផលិតផលឱសថ ផលិតផលគ្រឿងសម្អាង ផលិតផលម្ហូបអាហារ សារធាតុគីមីបន្ថែមលើផលិតផលម្ហូបអាហារ និងផលិតផលជាសម្ភារប្រើប្រាស់ទាំងឡាយណាដែលនៅក្នុងលក្ខខណ្ឌធម្មតា ពុំបង្កគ្រោះថ្នាក់ដល់សុខភាពអ្នកផលិត អ្នកដឹកជញ្ជូន អ្នកចែកចាយ និងអ្នកប្រើប្រាស់។

## ៣. និយមន័យ

- សារធាតុគីមី (Chemical Substances) សំដៅដល់ធាតុគីមី និងសមាសធាតុរបស់វាដែលមាននៅក្នុងធម្មជាតិ ឬបានមកពីដំណើរការផលិតកម្ម រួមទាំងសារធាតុបន្ថែមដែលចាំបាច់ ដើម្បីរក្សាឱ្យមានស្ថិរភាព នូវផលិតផលព្រមទាំងសារធាតុមិនសុទ្ធ ដែលទាញយកចេញពីដំណើរការផលិតកម្ម តែមិនរាប់បញ្ចូលសារធាតុរំលាយដែលអាចធ្វើការញែកចេញបាន ដោយមិនធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនៃសារធាតុគីមី ឬមិនធ្វើឱ្យប្រែប្រួលនូវធាតុបន្សំរបស់វា។
- ផលិតផលគីមី (Chemical Products) សំដៅដល់ល្បាយ ឬសូលុយស្យុង ដែលផ្សំឡើងដោយសារធាតុគីមីចំនួន ២ ឬច្រើនមុខដែលពុំមានប្រតិកម្មគីមីនឹងគ្នា។
- ផលិតផលគីមីប្រើប្រាស់ (Chemical Consumer Products) សំដៅដល់សារធាតុគីមី និងផលិតផលគីមីដែលមានលក្ខណៈជា

ផលិតផលសម្រេច ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព ហើយត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃជីវភាពរស់នៅ។

- ស្លាកសញ្ញាសារធាតុគីមី (Chemical Label) សំដៅលើព័ត៌មានសង្ខេបអំពីសារធាតុគីមី និងផលិតផលគីមីប្រើប្រាស់ អំពីភាពអាចបង្កគ្រោះថ្នាក់ អំពីការណែនាំសុវត្ថិភាពក្នុងការដឹកជញ្ជូន ថែរក្សាស្តុក ប្រើប្រាស់ វិធានការបង្ការ និងព័ត៌មានដែលពាក់ព័ន្ធនឹងប្រភពផលិតផល និងចែកចាយក្នុងទម្រង់ជារូបភាព និងអក្សរដែលបិទភ្ជាប់លើសម្ភារវេចខ្ចប់។
- ព័ត៌មានអំពីផលិតផល (Product Identifier)សំដៅដល់ព័ត៌មានអំពីអត្តសញ្ញាណរបស់ផលិតផលរួមមាន ឈ្មោះផលិតផលដែលមានឈ្មោះពាណិជ្ជកម្ម និងឈ្មោះគីមីទូទៅ ធាតុផ្សំសំខាន់ៗ បរិមាណ ពាណិជ្ជសញ្ញា លេខសម្គាល់អន្តរជាតិ កាលបរិច្ឆេទផលិត និងកំណត់កាលប្រើប្រាស់។
- រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ (Hazards Pictogram) សំដៅដល់រូបភាពដែលបញ្ជាក់សញ្ញានៃភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី ផលិតផលគីមី ប្រើប្រាស់ ដែលមានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃគោលការណ៍ណែនាំនេះ។
- អ្នកប្រើប្រាស់ សំដៅដល់អ្នកធ្វើការផ្ទាល់ជាមួយសារធាតុគីមីនៅកន្លែងធ្វើការ ដែលរួមទាំង សហគ្រាសខ្នាតតូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

# ៤. ភាតព្វកិច្ច ភារទទួលខុសត្រូវ និ១ភារៈកិច្ច

## ៤.១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមីនៅកន្លែងធ្វើការ និងតាមដាន វាយតម្លៃការអនុវត្តរបស់ និយោជក កម្មករនិយោជិត និងអ្នកប្រើប្រាស់ ក្នុងការប្រើសារធាតុគីមីនៅកន្លែងធ្វើការឱ្យមានប្រសិទ្ធភាព។

## ៤.២ អង្គការវិជ្ជាជីវៈ

### ក. សមាគមនិយោជក

សមាគមនិយោជក ត្រូវផ្សព្វផ្សាយ និងជំរុញឱ្យសមាជិករបស់ខ្លួនអនុវត្តតាមគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមីនេះឱ្យមានប្រសិទ្ធភាព។ សមាគមនិយោជក គួរណែនាំដល់រោងចក្រ សហគ្រាស ឱ្យបង្កើតផែនការ និងតាមដានការអនុវត្តនូវគោលការណ៍ណែនាំនេះឱ្យបានទៀងទាត់។

### ខ. និយោជក

និយោជក ត្រូវបង្កើតផែនការអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមីនេះឱ្យមានប្រសិទ្ធភាព។ និយោជក ត្រូវរក្សាព័ត៌មានអំពីសារធាតុគីមី និងការណែនាំរបស់អ្នកផ្គត់ផ្គង់ និងស្ថាប័នពាក់ព័ន្ធស្តីពីការប្រើប្រាស់សារធាតុគីមី ប្រកបដោយសុវត្ថិភាពដែលរួមមាន និមិត្តសញ្ញា លេខកូដ និងតារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី។

និយោជកត្រូវមានរបាយការណ៍អំពីការប្រើប្រាស់សារធាតុគីមី ហើយរបាយការណ៍នោះអាច មើលបានដោយនិយោជិតទាំងអស់ ឬអ្នកតំណាងរបស់គេ។ និយោជកត្រូវធ្វើការវាយតម្លៃហានិភ័យ នៃសារធាតុគីមីដែលមាននៅក្នុងកន្លែងធ្វើការ ដោយយោងលើឯកសារដែលបានពីអ្នកផ្គត់ផ្គង់ ក្រុមហ៊ុន ឬរោងចក្រដែលផលិតសារធាតុគីមី ដើម្បីធ្វើការបង្ការ និងគ្រប់គ្រងហានិភ័យដែលអាចកើតឡើង។

និយោជកត្រូវរកមធ្យោបាយឱ្យបានសមស្របដើម្បីការពារហានិភ័យដល់កម្មករនិយោជិតតាមរយៈការវាយតម្លៃហានិភ័យ និងការកំណត់ហានិភ័យ។ និយោជកត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីធ្វើការដោះស្រាយបញ្ហាមួយចំនួន ដូចជា គ្រោះថ្នាក់ដោយការសាយភាយសារធាតុគីមី អគ្គិភ័យ ឬផ្ទុះ។ ប្រសិនបើមិនអាចកាត់ផ្ដាច់ហានិភ័យបានទាំងស្រុង និយោជកត្រូវផ្ដល់សម្ភារការពារបុគ្គល ឬសម្លៀកបំពាក់ការពារសមរម្យ ដល់កម្មករនិយោជិតដោយមិនគិតថ្លៃ ដើម្បីការពារសុវត្ថិភាពរបស់ពួកគេ។

និយោជកត្រូវផ្ដល់ការបណ្ដុះបណ្ដាលអំពីការប្រើប្រាស់សារធាតុគីមី ជាពិសេសផ្អែកទៅលើតារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី (MSDS) ប្រកបដោយសុវត្ថិភាពដល់កម្មករនិយោជិត ឬតំណាងដែលជាអ្នកប្រើប្រាស់សារធាតុគីមីក្នុងរោងចក្រសហគ្រាស។

### គ. អង្គការនិយោជិត

អង្គការនិយោជិត ត្រូវផ្សព្វផ្សាយ និងជំរុញឱ្យសមាជិករបស់ខ្លួនអនុវត្តតាមគោលការណ៍ណែនាំស្ដីពីសុវត្ថិភាពសារធាតុគីមីឱ្យខ្ជាប់ខ្ជួន។ អង្គការ

និយោជិត ត្រូវតាមដានការអនុវត្តវិធានការសុវត្ថិភាព សារធាតុគីមីនៅកន្លែងធ្វើការ។

### ឃ. កម្មករនិយោជិត និងអ្នកប្រើប្រាស់

កម្មករនិយោជិត និងអ្នកប្រើប្រាស់ដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់លើបញ្ហាសុវត្ថិភាព និង សុខភាពរបស់ខ្លួន និងអ្នកដទៃ ដែលអាចរងផលប៉ះពាល់ដោយសារធាតុគីមី។ កម្មករនិយោជិត ត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមី និងការណែនាំផ្សេងៗទៀតរបស់និយោជក និងស្ថាប័នពាក់ព័ន្ធទាក់ទងនឹងសុវត្ថិភាពសារធាតុគីមី។ កម្មករនិយោជិត ត្រូវប្រើសម្ភារការពារបុគ្គលដែលបានផ្តល់ ឱ្យបានត្រឹមត្រូវ និងខ្ជាប់ខ្ជួន។ កម្មករនិយោជិត ត្រូវរាយការណ៍ភ្លាមៗទៅកាន់អ្នកគ្រប់គ្រង នូវស្ថានភាពណាមួយដែលអាចមានហានិភ័យដល់ខ្លួន ឬកម្មករនិយោជិតដទៃទៀត នៅកន្លែងធ្វើការ។

## ៤.៣ អ្នកផ្គត់ផ្គង់

អ្នកផ្គត់ផ្គង់ អ្នកផលិត អ្នកនាំចូល ឬអ្នកចែកចាយសារធាតុគីមី ត្រូវមានឯកសារ ឬព័ត៌មានទាក់ទងនឹងសារធាតុគីមីនីមួយៗជាចាំបាច់ដូចខាងក្រោម៖

ក. ដាក់ចំណាត់ថ្នាក់ និងការវាយតម្លៃសារធាតុគីមី
ខ. បិទសញ្ញាសម្គាល់ ឬនិមិត្តសញ្ញាសារធាតុគីមី
គ. បិទស្លាកសញ្ញាគ្រោះថ្នាក់សារធាតុគីមី
ឃ. ភ្ជាប់តារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី

អ្នកផ្គត់ផ្គង់ ត្រូវកំណត់ និងធ្វើការវាយតម្លៃនៃសារធាតុគីមីទាំងអស់ រួមទាំងសារធាតុផ្សំ ដែលបានផលិតឡើង។

### ៤.៤ អ្នកជំនាញ ឬអ្នកឯកទេសផ្នែកសារធាតុគីមី

អ្នកជំនាញ ឬអ្នកឯកទេសផ្នែកសារធាតុគីមី ត្រូវជួយផ្តល់ដំបូន្មាន ឬការបណ្តុះបណ្តាលដល់ ស្ថាប័នពាក់ព័ន្ធ ព្រមទាំងនិយោជក កម្មករ និយោជិត និងអ្នកប្រើប្រាស់អំពីសុវត្ថិភាពសារធាតុគីមីស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៥. ការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

### ៥.១ ការចាត់ថ្នាក់សារធាតុគីមី

ការចាត់ថ្នាក់ភាពបង្កគ្រោះថ្នាក់ ការដាក់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ និងទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាពសារធាតុគីមី ត្រូវអនុលោមទៅតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ។

### ៥.២ លក្ខណៈវិនិច្ឆ័យនៃការចាត់ថ្នាក់សារធាតុគីមី

លក្ខណៈវិនិច្ឆ័យនៃការចាត់ថ្នាក់សារធាតុគីមី ត្រូវផ្អែកលើមូលដ្ឋាននៃផលប៉ះពាល់របស់សារធាតុ គីមីទៅលើសុខភាពមនុស្ស សត្វ បរិស្ថាន និងលក្ខណៈរូបសាស្ត្ររបស់សារធាតុគីមី។

## ៤.៣ ការបិទស្លាកសញ្ញា

សារធាតុគីមី ដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានបិទស្លាកសញ្ញា សារធាតុគីមី នៅលើសម្ភារផ្ទុក វេចខ្ចប់ ដោយអនុលោមតាមប្រកាស និងសារាចរណែនាំរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី។

ចំណុចសំខាន់ៗដែលតម្រូវឱ្យមាននៅក្នុងស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារ វេចខ្ចប់សារធាតុគីមី មានជាអាទិ៍៖

១. ព័ត៌មានអំពីផលិតផល

២. រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់

៣. ពាក្យព្រមាន

៤. ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់

៥. ព័ត៌មានអំពីវិធានការបង្ការ ឬវិធីប្រើប្រាស់

៦. ព័ត៌មានអំពីផលិតករ ឬអ្នកផ្គត់ផ្គង់

ស្លាកសញ្ញាសារធាតុគីមីដែលត្រូវបិទនៅលើសម្ភារវេចខ្ចប់សារធាតុគីមី ត្រូវមានលក្ខណៈដូចតទៅ៖

- ងាយស្រួលអាន
- មើលឃើញច្បាស់
- មិនងាយរហែក ឬខូច
- មិនងាយបក ឬផ្តាច់ចេញពីសម្ភារវេចខ្ចប់
- មិនឆ្លកពណ៌ រលុបអក្សរ ឬរលុបរូបសញ្ញា

អក្សរដែលសរសេរលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារវេចខ្ចប់សារធាតុគីមី ត្រូវអនុវត្តដូចខាងក្រោម៖

ក. សម្រាប់សារធាតុគីមី ដែលបាននាំចូលពីបរទេសត្រូវមានបិទស្លាកសញ្ញាសារធាតុគីមីបន្ថែមជាភាសាខ្មែរ មុនពេលចែកចាយ ឬយកទៅប្រើប្រាស់។

ខ. សម្រាប់សារធាតុគីមី ដែលធ្វើការផលិត ឬវេចខ្ចប់ឡើងវិញនៅក្នុងស្រុក ត្រូវមានបិទស្លាកសញ្ញាសារធាតុគីមី ជាភាសាខ្មែរលើសម្ភារវេចខ្ចប់មុនពេលដឹកចេញពីទីតាំងផលិត ឬមុនពេលវេចខ្ចប់ឡើងវិញ។

គ. ចំពោះចំណុចដែលមានលក្ខណៈទូទៅ ពាក់ព័ន្ធនឹងសារធាតុគីមីដូចជា ឈ្មោះពាណិជ្ជកម្ម ឈ្មោះគីមីទូទៅ អាចអនុញ្ញាតឱ្យប្រើជាភាសាឡាតាំងបាន។

ទម្រង់ និងពណ៌របស់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារផ្ទុកវេចខ្ចប់នៃសារធាតុគីមី ត្រូវអនុលោមតាមការកំណត់នៃ ឯកសារបទដ្ឋានបច្ចេកទេស ស្ដីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី។

## ៦. តារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី

គ្រប់សារធាតុគីមីទាំងអស់ ដែលយកមកប្រើប្រាស់នៅកន្លែងធ្វើការត្រូវតែមានភ្ជាប់មកជាមួយតារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី និងត្រូវបកប្រែជាភាសាខ្មែរដែលកម្មករនិយោជិត ងាយអាន និងងាយយល់។ តារាង

ទិន្នន័យសុវត្ថិភាពសារធាតុគីមីនេះ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់នៅកន្លែងធ្វើការ។

សារធាតុគីមី ត្រូវតែមានភ្ជាប់ជាមួយនូវឯកសារព័ត៌មានអំពីសុវត្ថិភាព ដោយអនុលោមតាមប្រកាស សារាចរណែនាំ និងឯកសារបទដ្ឋានបច្ចេកទេស របស់ក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធ។

សម្រាប់សារធាតុគីមី ដែលបាននាំចូលពីបរទេស ត្រូវមានឯកសារព័ត៌មានអំពីសុវត្ថិភាពបន្ថែមជាភាសាខ្មែរ មុនពេលចែកចាយ ឬមុនយកទៅប្រើប្រាស់។

ទម្រង់គោលនៃទិន្នន័យសុវត្ថិភាពសម្រាប់សារធាតុគីមីមាន១៦ ចំនុចសំខាន់ៗ រួមមាន៖

ក. ការកំណត់ពីអត្តសញ្ញាណ នៃសារធាតុគីមី/ល្បាយ
ខ. ការកំណត់ពីភាពគ្រោះថ្នាក់
គ. សារធាតុផ្សំ និងព័ត៌មាន
ឃ. វិធានការសង្គ្រោះបឋម
ង. វិធានការពេលមានអគ្គិភ័យ
ច. វិធានការពេលមានការលេចធ្លាយ
ឆ. ការដឹកជញ្ជូន និងទុកដាក់
ជ. ការគ្រប់គ្រងផលប៉ះពាល់ និងការការពារខ្លួន
ឈ. លក្ខណៈរូប និងគីមីនៃសារធាតុគីមី
ញ. ប្រតិកម្មនៃសារធាតុគីមី
ត. ព័ត៌មាននៃភាពពុល
ថ. ព័ត៌មានទាក់ទងបរិស្ថាន
ទ. ការបោះចោលសំណល់សារធាតុគីមី

ធ. ព័ត៌មាននៃការដឹកជញ្ជូន
ន. ព័ត៌មានទាក់ទងបទប្បញ្ញត្តិច្បាប់
ដ. ព័ត៌មានផ្សេងៗទៀត

### ក. ការកំណត់ពីអត្តសញ្ញាណ នៃសារធាតុគីមី/ល្បាយ

ឈ្មោះរបស់វាដែលប្រើគួរតែដូចទៅនឹងស្លាកនៃសារធាតុគីមីដែលមានគ្រោះថ្នាក់ ដែលអាចជាឈ្មោះធម្មតា ឬឈ្មោះប្រើទូទៅនៅក្នុងការធ្វើពាណិជ្ជកម្ម។ ការប្រើឈ្មោះបន្ថែមលុះត្រាតែមានការបញ្ជាក់ពីអត្តសញ្ញាណរបស់សារធាតុគីមី/ល្បាយនោះ។ ឈ្មោះពេញ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់អ្នកផ្គត់ផ្គង់ គួរតែត្រូវបានបញ្ចូល។ លេខទូរស័ព្ទគ្រាអាសន្នគួរត្រូវបានផ្តល់ សម្រាប់ទាក់ទងពេលមានករណីបន្ទាន់។ គួរជាលេខក្រុមហ៊ុនផ្ទាល់ រឺក្រុមហ៊ុនប្រឹក្សាដែលត្រូវបានទទួលស្គាល់ ហើយដែលអាចទាក់ទងបានគ្រប់ពេលវេលា។

### ខ. ការកំណត់ពីភាពគ្រោះថ្នាក់

គ្រោះថ្នាក់ និងព័ត៌មានសំខាន់ៗដែលប៉ះពាល់ដល់សុខភាពរាងកាយ និងបរិស្ថាន ត្រូវតែ បញ្ជាក់ឱ្យច្បាស់នៅលើស្លាកសញ្ញានីមួយៗ។

### គ. សារធាតុផ្សំ និងព័ត៌មាន

សារធាតុផ្សំ និងព័ត៌មានរបស់សារធាតុគីមី អាចឱ្យនិយោជក ធ្វើការកំណត់ និងវាយតម្លៃអំពីហានិភ័យដែលអាចកើតមានឡើងនៅកន្លែងធ្វើការ។ ព័ត៌មានលម្អិតនៃគ្រឿងផ្សំជាទូទៅត្រូវបានផ្តល់ ក្នុងករណីហានិភ័យទាំងនោះមិនត្រូវបានវាយតម្លៃត្រឹមត្រូវ។ ការផ្តល់ព័ត៌មាន មានដូចខាងក្រោមនេះ

លើកលែងតែឈ្មោះ ឬសមាសភាពនៃការផ្សំនៅកន្លែងលាយដែលវាអាចជាព័ត៌មានសម្ងាត់ ដែលមិនត្រូវបានបញ្ចូលដូចនៅក្នុង ចំណុចដូចខាងក្រោម៖

(i) ការរៀបរាប់ពីសារធាតុផ្សំសំខាន់ៗ រួមមានធម្មជាតិគីមីរបស់វា

(ii) ការកំណត់អត្តសញ្ញាណ និងសមាសភាពគ្រឿងផ្សំដែលជាគ្រោះថ្នាក់នៃសុវត្ថិភាព និងសុខភាព

(iii) ការកំណត់អត្តសញ្ញាណ និងសមាសភាពផ្សំអតិបរមាដែលបានរកឃើញ ឬការលើសនូវសមាសភាពផ្សំដែលបានចាត់ជាគ្រោះថ្នាក់នៃសុវត្ថិភាព និងសុខភាព នៅក្នុងតារាងអនុញ្ញាតឬទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច ឬសមាសភាពហាមឃាត់ ពីការប្រើប្រាស់ច្រើនណាមួយដោយអាជ្ញាធរ។

### ឃ. វិធានសង្គ្រោះបឋម

វិធាននៃការសង្គ្រោះបឋម និងការជួយខ្លួនឯង ត្រូវតែបង្ហាញ និងពន្យល់ឱ្យបានច្បាស់ អំពីការជួយសង្គ្រោះ និងវិធានការចាំបាច់នានា។

### ង. វិធានការពេលមានអគ្គិភ័យ

តម្រូវការក្នុងការឆ្លើយតបនៅពេលមានគ្រោះថ្នាក់អគ្គិភ័យដោយសារធាតុគីមី គួររួមបញ្ចូល៖

- មធ្យោបាយ និងឧបករណ៍ពន្លត់អគ្គិភ័យដែលសមស្រប
- សម្ភារការពារពិសេសសម្រាប់អ្នកពន្លត់អគ្គិភ័យ

ផ្តល់ព័ត៌មានអំពីសារធាតុគីមីនៅពេលដែលមានភ្លើងឆេះ និងគ្រោះថ្នាក់ដោយសារចំហេះរបស់វា ក៏ដូចជាវិធានការបង្ការដែលត្រូវប្រើ។

### ច. វិធានការបង្ការគ្រោះថ្នាក់នៃការលេចធ្លាយ

គួរផ្ដល់ព័ត៌មានដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់ ពីសកម្មភាពដែលត្រូវធ្វើ នៅពេលដែលមានគ្រោះថ្នាក់នៃការលេចធ្លាយសារធាតុគីមីដែលសកម្មភាពទាំងនោះរួមមាន៖

- ការបង្ការផ្នែកសុវត្ថិភាព និងសុខភាពការងារ៖ យកចេញនូវប្រភពដែលអាចបណ្ដាលឱ្យឆេះ បង្កើតឱ្យមានលំហូរខ្យល់ចេញចូលគ្រប់គ្រាន់ និងផ្ដល់នូវសម្ភារការពារបុគ្គលដែលសមស្រប
- ការការពារបរិស្ថាន៖ រក្សាឱ្យឆ្ងាយពីប្រព័ន្ធលូបង្ហូរទឹក ត្រូវផ្ដល់ដំណឹងទៅឱ្យក្រុមឆ្លើយតបពេលមានអាសន្ន ក្នុងករណីចាំបាច់ត្រូវជូនដំណឹងដល់អ្នកដែលនៅជុំវិញអំពីហានិភ័យដែលអាចកើតមានឡើ
- របៀបនៃការធ្វើឱ្យមានសុវត្ថិភាព និងការលាងសម្អាត៖ ប្រើប្រាស់ឧបករណ៍សម្រាប់ស្រូបបឺត មធ្យោបាយ ឬសម្ភារណាដែលសមស្រប។ ចៀសវាងការប្រើប្រាស់ឧស្ម័ន ឬចំហាយទឹក ឬសារធាតុផ្សេងទៀតដែលមានប្រតិកម្មជាមួយសារធាតុគីមីនោះ
- ការហាមឃាត់៖ ហាមធ្វើសកម្មភាពទាំងឡាយណា ដែលអាចបង្កឱ្យមានគ្រោះថ្នាក់។

### ឆ. ការដឹកជញ្ជូន និងទុកដាក់

គួរផ្ដល់ព័ត៌មានដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់ អំពីលក្ខខណ្ឌដែលណែនាំដោយអ្នកផ្គត់ផ្គង់ សម្រាប់ការដឹកជញ្ជូន និងទុកដាក់ ប្រកបដោយសុវត្ថិភាព ដូចជា៖

- រៀបចំប្លង់ និងទីតាំងទុកសារធាតុគីមី នៅក្នុងបន្ទប់ ឬឃ្លាំងស្ដុកសន្និធិ
- ដាក់សារធាតុគីមីដាច់ដោយឡែកពីកន្លែងធ្វើការ
- ចៀសវាងដាក់សារធាតុដែលមានប្រតិកម្មជាមួយនឹងសារធាតុគីមី

- លក្ខខណ្ឌនៃការទុកដាក់ ឧ.សីតុណ្ហភាព សំណើម ឆ្ងាយពីពន្លឺព្រះអាទិត្យ និងមានខ្យល់ចេញចូល
- ចៀសវាងប្រភពដែលអាចឆេះ
- ណែនាំពីរបៀបដែលត្រូវអនុវត្ត និងរបៀបដែលត្រូវចៀសវាង

### ជ. ការគ្រប់គ្រងផលប៉ះពាល់ និងការការពារខ្លួន

គួរផ្តល់ព័ត៌មានដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់ អំពីតម្រូវការក្នុងការប្រើប្រាស់ និងប្រភេទសម្ភារការពារបុគ្គលឱ្យបានគ្រប់គ្រាន់ និងសមស្របនៅពេលប្រើប្រាស់សារធាតុគីមី។ នៅក្នុងករណីចាំបាច់អ្នកទទួលខុសត្រូវ គួរត្រួតពិនិត្យជាបឋម ហើយធ្វើការណែនាំបន្ថែមដើម្បីកាត់បន្ថយការប្រឈមទៅនឹងគ្រោះថ្នាក់ របស់កម្មករនិយោជិត និងអ្នកប្រើប្រាស់។

### ឈ. លក្ខណៈរូប និងគីមី នៃសារធាតុគីមី

ធ្វើការពណ៌នាដោយសង្ខេបអំពីលក្ខណៈរូបសាស្ត្រនៃសារធាតុគីមី តើសារធាតុគីមីនោះជាសារធាតុ រឹង រាវ ឧស្ម័ន មាន ឬគ្មានពណ៌ និងមាន ឬគ្មានក្លិន។

ការកំណត់ និងរៀបរាប់អំពីលក្ខណៈរូបសាស្ត្រនៃសារធាតុគីមី គួរតែអនុលោមទៅតាមបទដ្ឋានគតិយុត្តជាធរមាន ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធ។

### ញ. ប្រតិកម្ម នៃសារធាតុគីមី

គួរបញ្ជាក់ឱ្យកម្មករនិយោជិត និងអ្នកប្រើប្រាស់បានដឹង អំពីប្រតិកម្មដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ទៅតាមលក្ខខណ្ឌជាក់លាក់នីមួយៗ

និងបញ្ជាក់អំពីវិធានការចាំបាច់ដែលត្រូវចៀសវាងគ្រោះថ្នាក់ពីប្រតិកម្មសារធាតុគីមីនោះ។

### ដ. ព័ត៌មាននៃភាពពុល

គួរផ្តល់ព័ត៌មានដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់អំពីផលប៉ះពាល់ដល់រាងកាយ និងផ្លូវដែលអាចជ្រាបចូលទៅក្នុងរាងកាយ។ ផលប៉ះពាល់ទាំងនោះអាចមានលក្ខណៈ ស្រួចស្រាវ ឬរ៉ាំរ៉ៃ ទៅតាមរយៈពេលវែង ឬខ្លី ដែលអ្នកប្រើប្រាស់ប្រឈមជាមួយសារធាតុគីមីនោះ។

### ឋ. ព័ត៌មានទាក់ទងប្រព័ន្ធអេកូឡូហ្ស៊ី

ត្រូវរៀបរាប់អំពីផលប៉ះពាល់បរិស្ថាន ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ហើយនិយោជកត្រូវអនុវត្តនៅកន្លែងធ្វើការ។

### ឌ. ការបោះចោលកាកសំណល់សារធាតុគីមី

គួរផ្តល់ព័ត៌មានដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់ អំពីវិធីសាស្ត្រសុវត្ថិភាពក្នុងការបោះចោលកាកសំណល់ និងសម្ភារមានសារធាតុគីមីដែលអាចបង្កគ្រោះថ្នាក់ ទៅតាមការណែនាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

### ឍ. ព័ត៌មាននៃការដឹកជញ្ជូន

និយោជក ត្រូវផ្តល់ព័ត៌មានពីវិធានការបង្ការជាពិសេស ដល់អ្នកដឹកជញ្ជូនសារធាតុគីមី ចេញ ឬចូលកន្លែងធ្វើការ។

### ណ. ព័ត៌មានទាក់ទងច្បាប់ និងបទប្បញ្ញត្តិនានា

និយោជក ត្រូវផ្តល់ព័ត៌មាន និងដាក់ស្លាកសញ្ញាសំគាល់សារធាតុគីមីទាំងឡាយដែលមាន ប្រើប្រាស់នៅក្នុងកន្លែងធ្វើការដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### គ. ព័ត៌មានផ្សេងៗទៀត

ព័ត៌មានផ្សេងៗដែលមានសារៈសំខាន់ដល់សុវត្ថិភាព និងសុខភាពការងារ នៃកម្មករនិយោជិត គួរបញ្ចូលនៅក្នុងតារាងទិន្នន័យ។ ព័ត៌មានទាំងនោះអាចមានដូចជា៖ ការផ្តល់ដំបូន្មាន ការបណ្តុះបណ្តាល ការណែនាំពីវិធីសាស្ត្រក្នុងការប្រើប្រាស់ ការហាមឃាត់ .....។ល។

## ៧. វិធានការក្នុងការកំណត់ និងគ្រប់គ្រងហានិភ័យ

និយោជក ឬអ្នកមានសមត្ថភាព ដែលត្រូវបានតែងតាំងឱ្យទទួលខុសត្រូវផ្នែកសារធាតុគីមី គួររៀបចំនីតិវិធីក្នុងការប៉ាន់ប្រមាណដើម្បីកំណត់ និងវាយតម្លៃហានិភ័យសារធាតុគីមី និងរៀបចំវិធានការគ្រប់គ្រងហានិភ័យទាំងនោះឱ្យបានសមស្រប និងមានប្រសិទ្ធភាព។

### ៧.១. ការកំណត់ និងវាយតម្លៃហានិភ័យ

និយោជក ត្រូវចាត់តាំងឱ្យមានអ្នកទទួលខុសត្រូវដែលមានសមត្ថភាពធ្វើការប៉ាន់ប្រមាណដើម្បីកំណត់ និងវាយតម្លៃហានិភ័យសារធាតុគីមីទាំងអស់នៅកន្លែងធ្វើការជាប្រចាំ។

សារធាតុគីមីដែលនាំយកមកប្រើប្រាស់ក្នុងផលិតកម្ម ត្រូវមានប្រភពច្បាស់លាស់ ភ្ជាប់ជាមួយនូវឯកសារព័ត៌មានអំពីសុវត្ថិភាពសារធាតុគីមី និងមានការអនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ ព័ត៌មានអំពីសុវត្ថិភាពសារធាតុគីមីទាំងនោះត្រូវបញ្ជាក់អំពីកម្រិតហានិភ័យ ដើម្បីអាចធ្វើការប៉ាន់ប្រមាណបាននៅកន្លែងធ្វើការដែលមានប្រើសារធាតុគីមីទាំងនោះ។ ការកំណត់ និងវាយតម្លៃហានិភ័យមានបង្ហាញនៅក្នុងតារាងទី១ ដល់ទី៤ ខាងក្រោម។

**ការប៉ាន់ប្រមាណគួរផ្តោតលើ៖** ផលប៉ះពាល់ផ្នែកសុខភាព និងប្រតិបត្តិការ ការងារប្រចាំថ្ងៃ

- ផលប៉ះពាល់ផ្នែកសុខភាព គឺត្រូវគិតទៅលើសារធាតុគីមីអាចបង្កជំងឺស្រួចស្រាវ ឬរ៉ាំរ៉ៃ ដែលចូលក្នុងខ្លួនតាម៖
    - ផ្លូវដង្ហើម
    - ផ្លូវអាហារ និង
    - ជ្រាបចូលតាមស្បែក
- ប្រតិបត្តិការ ការងារប្រចាំថ្ងៃ គឺត្រូវធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ដោយគិតទៅលើ៖
    - បរិមាណសារធាតុគីមីដែលមានប្រើនៅកន្លែងធ្វើការ
    - វិធានប្រតិបត្តិការ ការងារដែលសមស្របទៅនឹងកន្លែងធ្វើការ (ការប្រើប្រាស់ ការទុកដាក់ ការដឹកជញ្ជូន និងការបោះចោលកាកសំណល់)

- ប្រព័ន្ធការពារសុវត្ថិភាពក្នុងពេលធ្វើការថែទាំ និង ជួសជុល
- ការបង្ការអគ្គិភ័យ ការផ្ទុះ និងប្រតិកម្មសារធាតុគីមី
- លក្ខខណ្ឌវិនិច្ឆ័យ និងវិធានការគ្រប់គ្រងហានិភ័យ
- ការត្រួតពិនិត្យគុណភាពខ្យល់នៅកន្លែងធ្វើការ ដែលប្រើប្រាស់សារធាតុគីមី

**តារាងទី ១៖ កម្រិតហានិភ័យ**

| **កម្រិត** | **ហានិភ័យ** | **ការប៉ាន់ប្រមាណកម្រិតហានិភ័យ** |
|---|---|---|
| ៥ | គ្រោះថ្នាក់ធ្ងន់ធ្ងរបំផុត | ស្លាប់ របួសធ្ងន់ធ្ងរបំផុតច្រើនកន្លែង និងមានជំងឺបណ្ដាលឱ្យស្លាប់ |
| ៤ | គ្រោះថ្នាក់ធ្ងន់ធ្ងរ | របួសធ្ងន់ធ្ងរ ឬមានជំងឺវិជ្ជាជីវៈដែលគំរាមគំហែងដល់អាយុជីវិត (ពិការដាច់អវៈយវៈ បាក់ឆ្អឹងធ្ងន់ធ្ងរ របួសច្រើនកន្លែង ជំងឺមហារីកបណ្ដាលមកពីការងារ ពុលស្រួចស្រាវ ពិការ និងថ្លង់) |
| ៣ | មធ្យម | របួស ឬមានជំងឺដែលទាមទារឱ្យមានការព្យាបាលវេជ្ជសាស្ត្រ (ដាច់រលាត់ស្បែក រលាកគ្រេច រលាកស្បែក ឈឺអវៈយវៈផ្នែកខាងលើ) |
| ២ | ស្រាល | រលាត់ ឬមានជំងឺ ដែលទាមទារត្រឹមតែការសង្គ្រោះបឋម (មុតបន្តិចបន្តួច ជាំ កន្ទួលរមាស់ មិនស្រួលខ្លួនរយៈពេលខ្លី) |
| ១ | ស្រាលបំផុត | របួសស្ទើរតែមិនចាប់អារម្មណ៍ |

**តារាងទី២ ៖ កម្រិតនៃភាពទំនងនឹងកើតមានហានិភ័យ**

| **កម្រិត** | **ភាពទំនងនឹងកើតមានហានិភ័យ** | **បរិយាយ** |
|---|---|---|
| ១ | កម្រនឹងកើតមាន | មិនរំពឹងថានឹងកើតមានទេ តែវានឹងអាចកើតឡើងបាន |
| ២ | ដែលទំនងមិនកើតមាន | មិនទំនងនឹងកើតមាន នៅក្នុងឱកាសធម្មតានោះទេ |
| ៣ | កើតមានម្តងម្កាល | អាចកើតមាន ឬដឹងថាកើតមាន |
| ៤ | កើតមានញឹកញាប់ | កើតមានជាធម្មតា |
| ៥ | កើតមានដដែលៗ | មានបទពិសោធន៍ដដែលៗ ឬម្តងហើយម្តងទៀត |

ដើម្បីគណនាកម្រិតហានិភ័យ ត្រូវយកកម្រិតហានិភ័យក្នុងតារាងទី១ គុណ កម្រិតនៃភាពទំនងនឹងកើតមានហានិភ័យក្នុងតារាងទី២។

**តារាងទី ៣ ៖ ការគណនាកម្រិតហានិភ័យ** ( ៥ x ៥ )

| ភាពទំនង នឹងកើតមាន / **កម្រិតហានិភ័យ** | កម្រនឹង កើតមាន (១) | ដែលទំនង មិនកើតមាន (២) | កើតមាន ម្តងម្កាល (៣) | កើតមាន ញឹកញាប់ (៤) | កើតមាន ដដែលៗ (៥) |
|---|---|---|---|---|---|
| គ្រោះថ្នាក់ធ្ងន់ធ្ងរបំផុត (៥) | ៥ | ១០ | ១៥ | ២០ | ២៥ |
| គ្រោះថ្នាក់ធ្ងន់ធ្ងរ (៤) | ៤ | ៨ | ១២ | ១៦ | ២០ |
| មធ្យម (៣) | ៣ | ៦ | ៩ | ១២ | ១៥ |
| ស្រាល (២) | ២ | ៤ | ៦ | ៨ | ១០ |
| ស្រាលបំផុត (១) | ១ | ២ | ៣ | ៤ | ៥ |

**តារាងទី៤៖ ការផ្តល់អនុសាសន៍នូវសកម្មភាពសម្រាប់កម្រិតហានិភ័យ**

| កម្រិតហានិភ័យ | ភាពដែលអាចទទួលយកកម្រិតហានិភ័យ | សកម្មភាព |
|---|---|---|
| (១៥-២៥) ខ្ពស់ | មិនអាចទទួលយកបាន | មានហានិភ័យខ្ពស់ដែលតម្រូវឱ្យចាត់វិធានការដោះស្រាយភ្លាមៗ ដើម្បីគ្រប់គ្រង និងកាត់បន្ថយគ្រោះថ្នាក់ឱ្យចុះមកនៅកម្រិតមធ្យម ឬកម្រិតទាបបំផុត មុននឹងធ្វើសកម្មភាពដូចក្នុងចំណុច ៧.២។ រាល់សកម្មភាពដែលបានធ្វើត្រូវកត់ត្រានៅក្នុងរបាយការណ៍ស្តីពីការប៉ាន់ប្រមាណហានិភ័យ។ |
| (៥-១២) មធ្យម | អាចទទួលយកបានខ្លះៗ | ហានិភ័យកម្រិតមធ្យមគឺទាមទារឱ្យមានការរៀបចំនូវវិធីសាស្ត្រដើម្បីគ្រប់គ្រងគ្រោះថ្នាក់ឱ្យមកនូវកម្រិតទាបបំផុតដែលអាចធ្វើទៅបាន រួចអាចអនុវត្តនូវវិធានការបណ្តោះសិន។ រាល់សកម្មភាពដែលបានធ្វើត្រូវកត់ត្រានៅក្នុងរបាយការណ៍ស្តីពីការប៉ាន់ប្រមាណហានិភ័យ។ |

| | | |
|---|---|---|
| (១-៤)<br>ទាប | អាចទទួលយកបាន | ហានិភ័យដែលកើតឡើងមានកម្រិតទាបបំផុត ដែលអាចទទួលយកបាន ហើយមិនត្រូវការចាត់វិធានការអ្វីបន្ថែមដែរ។ |

## ៧.២. វិធានការគ្រប់គ្រងហានិភ័យ

និយោជក ត្រូវចាត់វិធានការគ្រប់គ្រងហានិភ័យឱ្យបានសមស្របទៅនឹងប្រភេទការងារ និង បរិបទនៃកន្លែងធ្វើការនីមួយៗ ដោយយោងទៅលើលទ្ធផលនៃការវាយតម្លៃហានិភ័យសារធាតុគីមី។ វិធានការចាំបាច់ទាំងនោះរួមមាន៖

- ការលុបបំបាត់
- ការដាក់ជំនួស
- ការគ្រប់គ្រងបែបវិស្វកម្ម
- ការគ្រប់គ្រងបែបរដ្ឋបាល
- ការប្រើប្រាស់សម្ភារការពារបុគ្គល

អ្នកទទួលខុសត្រូវទាក់ទងនឹងសារធាតុគីមី ត្រូវត្រួតពិនិត្យ តាមដានវិធានការគ្រប់គ្រងហានិភ័យ ដើម្បីធានាថាវិធានការទាំងនោះ អនុវត្តប្រកបដោយប្រសិទ្ធភាព។

## ៧.៣. ការរក្សាទុក និងការផ្ទេរសារធាតុគីមី

សារធាតុគីមីដែលមានគ្រោះថ្នាក់ គួរតែត្រូវបានរក្សាទុកនៅក្នុងលក្ខខណ្ឌសមស្រប តាមការណែនាំរបស់អ្នកផលិត ដើម្បីធានាបាននូវសុវត្ថិភាពក្នុងការប្រើប្រាស់។ លក្ខណៈនៃសារធាតុគីមីគ្រោះថ្នាក់ទាំងនោះ មានដូចជា៖

- សារធាតុគីមីរាវងាយឆាបឆេះ
- ឧស្ម័នងាយឆាបឆេះ
- សារធាតុគីមីពុល
- សារធាតុគីមីកាត់ស្បែក ឬរលាកធ្ងន់ធ្ងរ
- សារធាតុគីមីមានផ្សែងពុលខ្លាំង ពេលមានអគ្គិភ័យ
- សារធាតុគីមីប៉ះជាមួយទឹក អាចបង្កជាឧស្ម័នអាចឆាបឆេះ
- សារធាតុគីមីមានអុកស៊ីតកម្ម
- សារធាតុគីមីងាយផ្ទុះឆេះ
- សារធាតុរឹងងាយឆាបឆេះ
- ឧស្ម័នក្រោមសម្ពាធខ្ពស់។ល។

ឃ្លាំងដាក់សារធាតុគីមី ត្រូវរៀបចំដាច់ដោយឡែក និងមានប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់ត្រឹមត្រូវ មិនត្រូវពន្លឺត្រង់នៃព្រះអាទិត្យ និងត្រូវមានប្រព័ន្ធការពារចាំបាច់ផ្សេងៗទៀត សម្រាប់ទប់ទល់ និងការបង្កឱ្យមានការប្រែប្រួលរូបភាព ការបែកធ្លាយ ហូរចេញ ឬការបង្កឱ្យផ្ទុះឆេះ។ វិធានការទុកដាក់សារធាតុគីមី មានដូចខាងក្រោម៖

- កំណត់បរិមាណសារធាតុគីមីឱ្យសមស្របក្នុងការរក្សាទុកក្នុងឃ្លាំង
- ដាក់សារធាតុគីមីទៅតាមប្រភេទរបស់វា បើសារធាតុគីមីដែលអាចមានប្រតិកម្មនឹងគ្នា ត្រូវដាក់ឱ្យដាច់ដោយឡែកពីគ្នា
- ធានាសុវត្ថិភាពក្នុងការចេញចូលកន្លែងរក្សាទុកសារធាតុគីមី ហាមមានប្រភពដែលអាចនាំមានចំហេះ
- ការទុកដាក់សារធាតុគីមី ត្រូវតែរក្សាទុកដាច់ដោយឡែកពីកន្លែងធ្វើការ និង អគារផលិតកម្ម
- ទុកដាក់ធុង ឬកំប៉ុងសារធាតុគីមីដែលប្រើរួចនៅទីកន្លែងដែលសមស្រប និងមានសុវត្ថិភាព
- ការលើកដាក់ និងផ្ទេរសារធាតុគីមី ត្រូវគិតពីសុវត្ថិភាពដោយមានប្រព័ន្ធ សុវត្ថិភាពសមស្រប និងមានការបណ្តុះបណ្តាលត្រឹមត្រូវ
- ដាក់ស្លាកសញ្ញា ទៅតាមសារធាតុគីមីនីមួយៗ

- រៀបចំនីតិវិធី និងប្រព័ន្ធតាមដានពេលមានអាសន្ន។

## ៧.៤. ការដឹកជញ្ជូន ឬបំលាស់ទី

ការដឹកជញ្ជូនសារធាតុគីមីដែលមានគ្រោះថ្នាក់ ត្រូវគោរពទៅតាមបទដ្ឋានបច្ចេកទេស និងការណែនាំរបស់ស្ថាប័នមានសមត្ថកិច្ច ដោយផ្តោតទៅលើ៖

- លក្ខណៈ និងបរិមាណសារធាតុគីមីដែលត្រូវដឹកជញ្ជូន
- លក្ខណៈសមស្របក្នុងការវេចខ្ចប់ និងការផ្ទុកសារធាតុគីមីដែលមានគ្រោះថ្នាក់ដើម្បីដឹកជញ្ជូន
- លក្ខណៈរថយន្តដែលត្រូវប្រើដើម្បីដឹកជញ្ជូន
- ផ្លូវដឹកជញ្ជូន
- ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពអ្នកដឹកជញ្ជូន
- ការដាក់ស្លាកសញ្ញា
- ការលើកដាក់
- នីតិវិធីគ្រប់គ្រងពេលអាសន្ន។

## ៧.៥. ការបោះចោលសំណល់សារធាតុគីមី

កាកសំណល់សារធាតុគីមីដែលគ្រោះថ្នាក់ ត្រូវទុកដាក់ដាច់ដោយឡែកពីកាកសំណល់ធម្មតា និងនៅឆ្ងាយពីកន្លែងធ្វើការ ឬអគារផលិតកម្ម។ កាកសំណល់ទាំងនោះ ត្រូវបានវាយតម្លៃពីកម្រិតហានិភ័យដែលប៉ះពាល់ដល់សុវត្ថិភាព សុខភាពសាធារណៈ និងបរិស្ថាន។ ការបោះចោលកាកសំណល់

ត្រូវអនុវត្តទៅតាមវិធានការបច្ចេកទេស ដែលកំណត់ដោយបទដ្ឋានគតិយុត្ត ជាធរមានរបស់ស្ថាប័នមានសមត្ថកិច្ច ដើម្បីលុបបំបាត់ ឬកាត់បន្ថយហានិភ័យ ឱ្យនៅកម្រិតទាបបំផុត។

## ៨. វិធានការការពារបុគ្គល

### ៨.១. សម្ភារការពារបុគ្គល

សម្ភារការពារបុគ្គល មិនត្រូវបានចាត់ទុកជាជម្រើសអាទិភាពចម្បង ដើម្បីធានាសុវត្ថិភាពដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាពជាងវិធានការផ្នែកវិស្វកម្ម វិធានការរដ្ឋបាល និងវិធានការសមស្របដទៃទៀតនោះទេ។ ក្នុងករណីដែលវិធានការខាងលើមិនអាចអនុវត្តបាន នោះទើបត្រូវចាត់វិធានការការពារបុគ្គល។ សម្ភារការពារបុគ្គលដូចជា៖ បរិក្ខារការពារផ្លូវដង្ហើម អាវ ស្បែកជើងសុវត្ថិភាព បរិក្ខារសម្រាប់ការពារមុខ ភ្នែក និងដៃ និងឧបករណ៍ការពារការចម្លងនៃអេឡិចត្រូស្តាតិក ត្រូវផ្តល់ដល់កម្មករនិយោជិត និងអ្នកប្រើប្រាស់ ដែលធ្វើការផ្នែកដែលមានសារធាតុគីមី ដើម្បីការពារឱ្យកាន់តែមានសុវត្ថិភាពបន្ថែមទៀត សម្រាប់កាត់បន្ថយគ្រោះថ្នាក់។ និយោជក ត្រូវរិះរកមធ្យោបាយ និងគំនិតផ្តួចផ្តើមជាបន្តបន្ទាប់ ដើម្បីធានាថាវិធានការកាពារ ត្រូវបានអភិវឌ្ឍ និងអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងគោលដៅសម្រាប់កាត់បន្ថយ និងលុបបំបាត់គ្រោះថ្នាក់នៅគ្រប់កម្រិតទាំងអស់ ។ កម្មវិធីបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់ និងការថែទាំសម្ភារការពារបុគ្គលចាំបាច់ ត្រូវរៀបចំឡើងដល់កម្មករនិយោជិតដែលធ្វើការផ្នែកដែលមានសារធាតុគីមី ។ សម្ភារការពារបុគ្គលទាំងនោះ ត្រូវមានការថែទាំ គ្រប់គ្រង និងផ្លាស់ប្តូរ ក្នុងករណីមានការខូចខាត មិនអាចប្រើប្រាស់បាន ឬហួសកាលបរិច្ឆេទ នៃការប្រើប្រាស់។

### ៨.២. ឧបករណ៍ ឬបរិក្ខារការពារផ្លូវដង្ហើម

ឧបករណ៍ការពារផ្លូវដង្ហើម ចាំបាច់ត្រូវជ្រើសរើសយកមកប្រើប្រាស់ឱ្យស្របតាមការកំណត់ នៃច្បាប់ជាតិ ឬបទដ្ឋានជាតិ និងអន្តរជាតិ និងត្រូវមានការបញ្ជាក់ទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចពីភាពសមស្របនៃឧបករណ៍ការពារផ្លូវដង្ហើម ទៅតាមប្រភេទសារធាតុគីមីដែលគ្រោះថ្នាក់ និងស្តង់ដាកម្រិតអនុញ្ញាត នៃការស្រូបចូល ។

## រូបភាពទី១៖ លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសឧបករណ៍ ឬបរិក្ខារការពារផ្លូវដង្ហើម

ការកំណត់កម្រិតគ្រោះថ្នាក់របស់សារធាតុគីមីដែលកម្មករនិយោជិតប្រើប្រាស់ដោយពិនិត្យលើតារាងទិន្នន័យសុវត្ថិភាពសារធាតុគីមីដែលភ្ជាប់មកជាមួយសារធាតុគីមីនោះ

↓

ការវិភាគគោលការណ៍គ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ ដោយគិតគូរលើវិធានការជំនួស ឬវិស្វកម្ម (ប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់)

↓

ការវាស់វែងគុណភាពខ្យល់នៅប៉ុស្តិ៍ការងារ ដោយវាយតម្លៃអំពីបរិមាណ ឬកំហាប់នៃសារធាតុគីមីដែលមាននៅក្នុងខ្យល់ តើវាមានបរិមាណ ឬកំហាប់ខ្ពស់ និងក្រោមកម្រិតអនុញ្ញាតនៃការស្រូបចូលដែរឬទេ?

↓

កំណត់ប្រភេទនៃឧបករណ៍ ឬបរិក្ខាការពារផ្លូវដង្ហើមដែលសមស្របក្នុងការប្រើប្រាស់ដោយវិភាគលើកម្រិតអនុញ្ញាតនៃការស្រូបចូល និងផលប៉ះពាល់

↓

រៀបចំផែនការគ្រប់គ្រងឧបករណ៍ ឬបរិក្ខាការពារផ្លូវដង្ហើម រួមមានការធ្វើតេស្តភាពសមស្រប ការបណ្តុះបណ្តាល និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរ

### ៨.៣. សម្លៀកបំពាក់ការពារ

ការជ្រើសរើសសម្លៀកបំពាក់ការពារជាមួយសារធាតុគីមី ចាំបាច់ត្រូវផ្អែកលើចំណុចដូចខាងក្រោម៖

(ក) សមត្ថភាពនៃវត្ថុធាតុដើមដែលវាត្រូវបានផលិតដើម្បីទប់ទល់នឹងការជ្រាបចូលដោយសារធាតុគីមី ដែលមានគ្រោះថ្នាក់

(ខ) ភាពគ្រប់គ្រាន់នៃការរចនា ភាពសមស្របនៃសម្លៀកបំពាក់ការពារនឹងត្រូវស្របតាមគោលបំណងនៃការប្រើប្រាស់

(គ) បរិស្ថានដែលត្រូវយកមកពាក់ ឬប្រើប្រាស់

(ឃ) សម្លៀកបំពាក់ដែលអាចការពារធូលី

(ង) សម្លៀកបំពាក់ការពារ ដែលអាចការពារអគ្គិភ័យក្នុងករណីមានសារធាតុគីមីដែលងាយឆេះ

(ច) ភាពចាំបាច់ក្នុងការបង្ការអគ្គិភ័យ ឬការផ្ទុះកើតឡើង ដោយសារចរន្តអគ្គិសនី។

### ៨.៤. ការថែទាំ រក្សាទុក និងត្រួតពិនិត្យ

ការថែទាំ រក្សាទុក និងត្រួតពិនិត្យសម្ភារការពារបុគ្គល ចាំបាច់ត្រូវមានការចូលរួមពីនិយោជក និងកម្មករនិយោជិត នៅកន្លែងធ្វើការ។ និយោជកមានកាតព្វកិច្ចរៀបចំឱ្យមាននូវបទបញ្ជាការងារសម្រាប់ការថែទាំ រក្សាទុក និងត្រួតពិនិត្យរាល់ឧបករណ៍ ឬបរិក្ខារការពារបុគ្គលដែលបានផ្ដល់ដល់កម្មករនិយោជិត ព្រមទាំងណែនាំកម្មករនិយោជិត អំពីបទបញ្ជាការងារទាំងនោះ។ រាល់ឧបករណ៍ ឬបរិក្ខារការពារបុគ្គលទាំងអស់ ត្រូវតែថែទាំក្នុងស្ថានភាពល្អ និងផ្លាស់ប្ដូរនៅពេលដែលឧបករណ៍ ឬបរិក្ខារការពារបុគ្គលទាំងនោះ មិនអាចប្រើប្រាស់បាន ដោយមិនគិតថ្លៃ។ ដើម្បីធានាការថែទាំ រក្សាទុក និងត្រួតពិនិត្យ

ឱ្យបានត្រឹមត្រូវ និយោជក និងកម្មករនិយោជិត ចាំបាច់មានភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម៖

(ក) ឧបករណ៍ ឬបរិក្ខារការពារ មិនត្រូវប្រើឱ្យហួសកាលបរិច្ឆេទផលិតនោះទេ

(ខ) កម្មករនិយោជិត ត្រូវថែរក្សាឧបករណ៍ ឬបរិក្ខារការពារបុគ្គលដែលបានផ្តល់ឱ្យបានត្រឹមត្រូវ

(គ) ឧបករណ៍ការពារផ្លូវដង្ហើម លើកលែងតែឧបករណ៍ជំនួយដកដង្ហើមដែលអាចផ្លាស់ប្តូរបាន គឺត្រូវសម្អាត សម្លាប់មេរោគ និងធ្វើតេស្តឡើងវិញ បន្ទាប់ពីហួសរយៈពេលបញ្ជាក់ និងទទួលស្គាល់ដោយច្បាប់ជាតិ ឬស្តង់ដារជាតិ ឬអន្តរជាតិ នៃស្ថាប័នមានសមត្ថកិច្ច

(ឃ) ត្រូវរក្សាកំណត់ត្រាអំពីការថែទាំ ការសម្លាប់មេរោគ និងការត្រួតពិនិត្យស្ថានភាព និង គុណវិបត្តិណាមួយរបស់ ឧបករណ៍ បរិក្ខារការពារផ្លូវដង្ហើម ដោយអនុវត្តឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

(ង) អ្នកធ្វើតេស្ត ដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវសម្រាប់ការងារធ្វើតេស្តនេះ ត្រូវផ្ទៀងផ្ទាត់លើកំណត់ត្រានៃការថែទាំ ការសម្លាប់មេរោគ និងការត្រួតពិនិត្យស្ថានភាព ឧបករណ៍បរិក្ខារការពារផ្លូវដង្ហើមនោះ

(ច) និយោជក ត្រូវរៀបចំឱ្យមានកន្លែងសម្រាប់បោកគក់ ការសម្អាត ការសម្លាប់មេរោគ និងការត្រួតពិនិត្យសម្លៀកបំពាក់ការពារ ឬឧបករណ៍ និងបរិក្ខារការពារបុគ្គលដែលបានប្រើប្រាស់ និងដែលប្រឡាក់សារធាតុគីមី ។ ហាមដាច់ខាតកម្មករនិយោជិត

បោកគក់ សម្អាត ឬរក្សាទុកឧបករណ៍ និងបរិក្ខាការពារបុគ្គល ដែលប្រឡាក់សារធាតុគីមី នៅផ្ទះ ឬកន្លែងស្នាក់នៅ ។

(ឆ) និយោជកត្រូវយកចិត្តទុកដាក់បន្ថែមទៀត នៅពេលមានកិច្ចសន្យាជួលសេវាកម្មបោកគក់ សម្អាត ដើម្បីធានាថាអ្នកម៉ៅការ ឬភាគីនៃកិច្ចសន្យា បានយល់ច្បាស់អំពីការប្រុងប្រយ័ត្នចាំបាច់ ក្នុងការប្រមូលសម្លៀកបំពាក់ការពារដែលមានប្រឡាក់សារធាតុគីមី ។

## ៩. ការឆ្លើយតបនៅគ្រាអាសន្ន

កន្លែងធ្វើការងារដែលមានប្រើប្រាស់សារធាតុគីមី ត្រូវរៀបចំនីតិវិធីឆ្លើយតបបន្ទាន់នៅគ្រាអាសន្ន ដូចខាងក្រោម៖

### ៩.១. វិធានការឆ្លើយតបនៅគ្រាអាសន្ន

និយោជក ឬអ្នកមានសមត្ថភាពដែលត្រូវបានតែងតាំងឱ្យទទួលខុសត្រូវផ្នែកសារធាតុគីមី គួររៀបចំ ត្រៀមដោះស្រាយរាល់គ្រោះថ្នាក់ និងស្ថានភាពអាសន្ន ទៅតាមការណែនាំរបស់ស្ថាប័នជំនាញ ឬកំណត់ដោយការវាយតម្លៃហានិភ័យដែលអាចកើតមានឡើង ដោយការប្រើប្រាស់សារធាតុគីមី នៅកន្លែងធ្វើការគ្រប់ពេលវេលា ។

នីតិវិធីនៃការរៀបចំត្រៀមដោះស្រាយរាល់គ្រោះថ្នាក់ និងស្ថានភាពអាសន្នរួមមាន៖ បច្ចុប្បន្នភាព ព័ត៌មាន តារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី បទពិសោធន៍ និងការផ្លាស់ប្តូរសកម្មភាពការងារ ទាក់ទងនឹងការប្រើប្រាស់សារធាតុគីមី។ កម្មករនិយោជិត និងអ្នកប្រើប្រាស់សារធាតុគីមី គួរតែទទួល

បានការបណ្តុះបណ្តាលស្តីអំពី៖

(ក) ចាត់ចែងឱ្យមានការចុចកណ្ដឹងពេលអាសន្ន

(ខ) ចាត់ចែងការហៅរកជំនួយបន្ទាន់សមស្រប នៅក្នុងទីតាំង ឬនៅខាងក្រៅកន្លែងធ្វើការ ឧទា. ហៅរកសេវាកម្មពន្លត់អគ្គិភ័យ ក្នុងករណីមានអគ្គិភ័យ និងជំនួយសង្គ្រោះបន្ទាន់

(គ) ការប្រើប្រាស់សម្ភារការពារបុគ្គល

(ឃ) ការជម្លៀសខ្លួនពីទីតាំង ឬកន្លែងធ្វើការ ព្រមទាំងច្រកចេញ និងផ្លូវរត់គេចនៅគ្រាអាសន្ន

(ង) សកម្មភាពកាត់បន្ថយឧប្បត្តិហេតុនានាដូចជា៖ គ្រប់គ្រងការឆេះ ការលេចធ្លាយ ការកំពប់ និងបម្រាមជាក់លាក់នានាដែលនាំឱ្យមានគ្រោះថ្នាក់ ។

(ច) ការជម្លៀសខ្លួនអ្នកមានទីតាំងក្បែរកន្លែងកើតហេតុ

## ៩.២. ការសង្គ្រោះបឋម

សារធាតុគីមីអាចចូលក្នុងខ្លួនមនុស្ស តាមរយៈការស្រូបចូលតាមផ្លូវដង្ហើម ការលេបចូលតាមផ្លូវអាហារ ការជ្រាបចូលតាមស្បែក ឬភ្នែក។ ប៉ះពាល់ដល់សុខភាពមនុស្សអាចមានលក្ខណដូចតទៅ៖

១. **ស្រួចស្រាវ៖** គឺពេលសារធាតុគីមី ស្រូបចូលតាមច្រមុះ ឬលេបចូលតាមមាត់ ឬជ្រាបចូលតាមស្បែក បណ្តាលឱ្យប៉ះពាល់សុខភាពភ្លាមៗ ដែលមានឥទ្ធិពលឆាប់រហ័ស និងមានរយៈពេលខ្លី។ ជាទូទៅផលប៉ះពាល់អាចមានរោគសញ្ញាដូចជា វិលមុខ ក្អួតចង្អោរ ប្រតិកម្មស្បែករមាស់ រលាកស្បែក ដួលសន្លប់។

២. **រាំរ៉ៃ៖** គឺពេលសារធាតុគីមី ចូលក្នុងខ្លួនក្នុងរយៈពេលច្រើនខែ ឬឆ្នាំ បណ្តាលឱ្យប៉ះពាល់សុខភាពរ៉ាំរ៉ៃដូចជា មហារីក ខូចថ្លើម តម្រងនោម និងប្រព័ន្ធប្រសាទ។ គ្រោះថ្នាក់ទៅតាមប្រភេទនៃសារធាតុគីមីនីមួយៗ និងទៅតាមរយៈពេលទទួលរងសារធាតុគីមីទាំងនោះ ដូចជា មហារីកសួត ថ្លើម ស្បែក.....។

៣. **បង្កគ្រោះថ្នាក់ដល់ការបង្កកំណើត៖** ការប្រើប្រាស់សារធាតុគីមីរយៈពេលយូរអាចបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កោសិកាមេជីវិតស្ត្រី និងទឹកកាមបុរស ពិសេសគឺទារកក្នុងផ្ទៃ។

***របៀបសង្គ្រោះ ៖***

របៀបសង្គ្រោះអ្នករងគ្រោះដោយសារធាតុគីមី គឺមានលក្ខណៈផ្សេងៗពីគ្នា យោងតាមផលប៉ះពាល់របស់វា។ ការសង្គ្រោះត្រូវយោងទៅតាមការណែនាំដែលមាននៅក្នុងតារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី។ ប៉ុន្តែការណែនាំខាងក្រោមនេះគ្រាន់តែជាវិធានការនៃការសង្គ្រោះបឋមតែប៉ុណ្ណោះ។

**ក. សារធាតុគីមីចូលភ្នែក**

**រោគសញ្ញា៖** ឈឺ ផ្សារ ក្រហាយ រមាស់ភ្នែក ហូរទឹកភ្នែក ហើមត្របកភ្នែក ស្រវាំង និងក្រហមភ្នែក

**ការសង្គ្រោះបឋម**

- សូមកុំញីភ្នែក និងបិទភ្នែក បើភ្នែកត្រូវបានបិទដោយសារតែការឈឺចាប់ និងការកន្ត្រាក់ សូមបើកភ្នែកវិញដោយថ្នមៗ
- ដើម្បីកាត់បន្ថយការប្រឈមនៃការពិការភ្នែក និងការរលាកភ្នែក ត្រូវលាងសម្អាតដោយទឹកស្អាតឱ្យបានយ៉ាងតិច១៥នាទី។ ដើម្បីលាងសម្អាតភ្នែកទាំងពីរឱ្យបានល្អ គេអាចប្រើ

ឧបករណ៍លាងភ្នែក ឬមធ្យោបាយបង្ហូរទឹកដាក់ភ្នែកផ្សេងៗទៀត

- គ្របភ្នែកដែលបើកទាំងពីរ ដោយកន្សែង ឬក្រណាត់ស្អាត (ទោះបីរបួសតែភ្នែកម្ខាងក៏ដោយ) រួចបញ្ជូនជនរងគ្រោះទៅកាន់មន្ទីរពេទ្យ ឬមណ្ឌលសុខភាព ដែលនៅជិតបំផុត។

***ចំណាំ៖*** *ផ្តល់ព័ត៌មានអំពីសារធាតុគីមី ផលិតផលគីមី និង ផលិតផលគីមីប្រើប្រាស់ ដែលបង្កគ្រោះថ្នាក់នោះ ដល់អ្នកសង្គ្រោះ និងអ្នកមានសមត្ថកិច្ច។*

**ខ.សារធាតុគីមីជ្រាបចូលតាមស្បែក**

**រោគសញ្ញា៖** រមាស់ស្បែក ស្បែកឡើងក្រហម កន្ទួល ពងបែក មានអារម្មណ៍ត្រជាក់ស្បែក និង ស្ពឹក និងអាចពិបាកដកដង្ហើម។

**ការសង្គ្រោះបឋម**

- លាងសម្អាតដោយទឹកស្អាតរយៈពេលយ៉ាងតិច១៥នាទី នៅកន្លែងរបួសឱ្យបានឆាប់តាមដែលអាចធ្វើបាន
- ដោះសម្លៀកបំពាក់ ឬគ្រឿងអលង្ការ ដែលប៉ះពាល់ជាមួយសារធាតុគីមី ចេញឱ្យអស់
- ត្រូវលាងសម្អាត ឬងូតទឹកផ្លាស់ប្តូរសម្លៀកបំពាក់ ស្បែកជើងដែលប៉ះពាល់ជាមួយសារធាតុគីមីជាបន្ទាន់

***ចំណាំ៖*** *ផ្តល់ព័ត៌មានអំពីសារធាតុគីមី ដែលបង្កគ្រោះថ្នាក់នោះ ដល់អ្នកសង្គ្រោះ និងអ្នកមានសមត្ថកិច្ច។*

**គ. លេបចូលតាមផ្លូវអាហារ**

**រោគសញ្ញា៖** វិលមុខ ក្អួត ចង្អោរ ពិបាកដកដង្ហើម ឬបាត់បង់ស្មារតី

**ការសង្គ្រោះបឋម**

- ពិនិត្យមើលផ្លូវដង្ហើម ( មានស្ទះ ឬយ៉ាងណា)
- ដាក់ជនរងគ្រោះនៅដំណេកសុវត្ថិភាពក្នុងករណីមានក្អួត
- រៀបចំធ្វើចលនាបេះដូងប្រសិនបើជនរងគ្រោះបាត់បង់ចង្វាក់បេះដូង
- សូមកុំផ្តល់អាហារឱ្យជនរងគ្រោះ (សូម្បីតែទឹក) មុនពេលវេជ្ជបណ្ឌិតអនុញ្ញាត

*ចំណាំ៖*

*- បិទស្លាកសញ្ញានៅលើសារធាតុគីមីដែលមានប្រើប្រាស់ដោយយកចិត្តទុកដាក់ ដើម្បីទប់ស្កាត់ គ្រោះថ្នាក់ ដែលអាចកើតឡើងដោយចៃដន្យ*

*- ផ្តល់ព័ត៌មានអំពីសារធាតុគីមី ដែលបង្កគ្រោះថ្នាក់នោះដល់អ្នកសង្គ្រោះ និងអ្នកមានសមត្ថកិច្ច។*

**ង. ស្រូបចូលតាមផ្លូវដង្ហើម**

**រោគសញ្ញា៖** វិលមុខ ក្អួតចង្អោរ ពិបាកដកដង្ហើម ឬបាត់បង់ស្មារតី

**ការសង្គ្រោះបឋម**

- ពិនិត្យមើលផ្លូវដង្ហើម ( មានស្ទះ ឬយ៉ាងណា)
- ដាក់ជនរងគ្រោះនៅដំណេកសុវត្ថិភាពក្នុងករណីមានក្អួត
- រៀបចំធ្វើចលនាដង្ហើម និងបេះដូង ប្រសិនបើជនរងគ្រោះបាត់បង់ដង្ហើម និងចង្វាក់បេះដូង

*ចំណាំ៖*

*- បិទស្លាកសញ្ញានៅលើសារធាតុគីមីដែលមានប្រើប្រាស់ដោយយកចិត្តទុកដាក់ ដើម្បីទប់ស្កាត់ គ្រោះថ្នាក់ ដែលអាចកើតឡើងដោយចៃដន្យ*

*- ផ្តល់ព័ត៌មានអំពីសារធាតុគីមី ដែលបង្កគ្រោះថ្នាក់នោះ ដល់អ្នកសង្គ្រោះ និងអ្នកមានសមត្ថកិច្ច។*

## ១០. ការបណ្តុះបណ្តាល និងព័ត៌មាន

និយោជកមានកាតព្វកិច្ចចាំបាច់ផ្តល់ការបណ្តុះបណ្តាលអំពីសុវត្ថិភាពសារធាតុគីមី ដែលប្រើប្រាស់នៅក្នុងកន្លែងធ្វើការ ទៅដល់គ្រប់កម្មករនិយោជិតទាំងអស់ដែលពាក់ព័ន្ធ ឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការបណ្តុះបណ្តាលនោះ ត្រូវធ្វើជាទៀងទាត់ចំពោះកម្មករនិយោជិត ដែលកំពុងបំពេញការងារ និងចូលធ្វើការដំបូង ជាពិសេសចំពោះផលិតផលគីមីថ្មី មុននឹងអនុញ្ញាតឱ្យកម្មករនិយោជិតប្រើប្រាស់។ ការបណ្តុះបណ្តាលនេះ ត្រូវធ្វើដោយអ្នកបច្ចេកទេស និងធ្វើក្នុងម៉ោងធ្វើការ ហើយកម្មករនិយោជិតដែលជាសិក្ខាកាមត្រូវទទួលបានប្រាក់ឈ្នួលជាធម្មតា ។

ការបណ្តុះបណ្តាល និងផ្តល់ព័ត៌មានស្តីពីសុវត្ថិភាពសារធាតុគីមី ដល់កម្មករនិយោជិត៖

- ការបណ្តុះបណ្តាលដល់កម្មករនិយោជិតចូលធ្វើការដំបូង ទើបត្រឡប់មកធ្វើការក្រោយការឈប់សម្រាករយៈពេលយូរ (លើសពី១ខែ) និងប្តូរបុស្តិ៍ការងារ

- ការបណ្ដុះបណ្ដាលដោយឡែកទៅតាមប្រភេទនៃសារធាតុគីមីនីមួយៗ (ការដឹកជញ្ជូន ការស្តុកទុក ការផ្ទេរ ការលាយ ការប្រើប្រាស់ និងការបោះចោលកាកសំណល់ ព្រមទាំងវិធានការការពារបុគ្គល)
- ការបណ្ដុះបណ្ដាលស្ដីពី វិជ្ជាសង្គ្រោះបឋម និងសុវត្ថិភាពអគ្គិភ័យ
- ការបិទផ្សព្វផ្សាយស្ដីពីសុវត្ថិភាពសារធាតុគីមី ទៅតាមក្ដារព័ត៌មានឃ្លាំងស្តុកទុកសារធាតុគីមី និងតាមប៉ុស្តិ៍ការងារ
- ការរៀបចំជាយុទ្ធនាការផ្សព្វផ្សាយ ឬការធ្វើបង្ហាញពីវិធីសាស្ត្រអនុវត្តដែលមានសុវត្ថិភាព រួមទាំងវិធីសាស្ត្រក្នុងការប្រើប្រាស់សម្ភារការពារបុគ្គល និងសម្ភារការពាររួម...។ល។

និយោជក ឬអ្នកគ្រប់គ្រង ត្រូវធ្វើការពិនិត្យតាមដានការអនុវត្តរបស់កម្មករនិយោជិតអំពីហានិភ័យពាក់ព័ន្ធទៅនឹងសុវត្ថិភាព និងសុខភាពការងារក្រោយពីមានការបណ្ដុះបណ្ដាល និងណែនាំរួច។

## ១១. ការពិនិត្យតាមដាន និងវាយតម្លៃ

និយោជក ឬអ្នកមានសមត្ថភាពដែលត្រូវបានតែងតាំងឱ្យទទួលខុសត្រូវផ្នែកសារធាតុគីមី ត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃពីហានិភ័យសារធាតុគីមីដែលពាក់ព័ន្ធ ទៅតាមកន្លែងធ្វើការនីមួយៗ។ ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃនេះ ត្រូវរៀបចំជាបញ្ជីផ្ទៀងផ្ទាត់ដែលសមស្របនិងមានអ្នកទទួលខុសត្រូវ និងពេលវេលាអនុវត្តច្បាស់លាស់។

**ឧទាហរណ៍អំពី**

## ការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីកែលម្អ ការគ្រប់គ្រងសារធាតុគីមីនៅ

..........................[ឈ្មោះរោងចក្រ សហគ្រាស]

| ល.រ | ចំណុចត្រូវត្រួតពិនិត្យ | បាទ/ចាស | ទេ | យោបល់ ឬកែលម្អ |
|---|---|---|---|---|
| **ភាតព្វកិច្ច ការទទួលខុសត្រូវ និងភារៈកិច្ច** | | | | |
| ១ | និយោជកបង្កើតផែនការអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមី | | | |
| ២ | និយោជកបានផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមី | | | |
| ៣ | និយោជកផ្សព្វផ្សាយរបាយការណ៍អំពីការកំណត់ហានិភ័យ និងការប្រើប្រាស់សារធាតុគីមី | | | |
| ៤ | កម្មករនិយោជិត អនុវត្តគោលការណ៍ណែនាំ នេះទៅតាមផែនការនៅតាមកន្លែងធ្វើការ | | | |

| | | | | |
|---|---|---|---|---|
| ៥ | កម្មករនិយោជិត ចូលរួមវគ្គបណ្តុះបណ្តាល និងតាមដានរាល់ព័ត៌មានដែលបានផ្សព្វផ្សាយ | | | |
| **ការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី** | | | | |
| ៦ | មានចាត់ថ្នាក់ភាពបង្កគ្រោះថ្នាក់ ការដាក់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ | | | |
| ៧ | មានបិទស្លាកសញ្ញាសារធាតុគីមី ដែលអ្នកប្រើប្រាស់អាចយល់បាន នៅលើសម្ភារវេចខ្ចប់សារធាតុគីមី | | | |
| **តារាងទិន្នន័យសារធាតុគីមី** | | | | |
| ៨ | ទម្រង់គោលនៃតារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី បង្ហាញទិន្នន័យដែលទាក់ទងនឹង ១៦ចំណុច (ដូចមានបញ្ជាក់ក្នុងចំណុចទី ៦ នៃគោលការណ៍ណែនាំនេះ) | | | |
| ៩ | មានតារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី ទាំងអស់ដែលបានប្រើនៅក្នុងសហគ្រាស | | | |

| | | | | |
|---|---|---|---|---|
| ១០ | តារាងទិន្នន័យសុវត្ថិភាពសារធាតុគីមីត្រូវបកប្រែជាភាសាខ្មែរ | | | |
| ១១ | តារាងទិន្នន័យសុវត្ថិភាពសារធាតុគីមី ត្រូវបានបិទផ្សព្វផ្សាយឱ្យកម្មករនិយោជិតបានងាយមើលឃើញ | | | |
| **វិធានការក្នុងការកំណត់ និងគ្រប់គ្រងហានិភ័យ** | | | | |
| ១២ | មានការកំណត់ និងវាយតម្លៃកម្រិតហានិភ័យសារធាតុគីមីដែលប្រើប្រាស់នៅកន្លែងធ្វើការ | | | |
| ១៣ | វិធានការចាំបាច់ដើម្បីគ្រប់គ្រងហានិភ័យ (ដូចជា៖ ការលុបបំបាត់ ការដាក់ជំនួស ការគ្រប់គ្រងបែបវិស្វកម្ម ការគ្រប់គ្រងបែបរដ្ឋបាល និងការប្រើប្រាស់សម្ភារការពារបុគ្គល) | | | |
| ១៤ | កំណត់បរិមាណសារធាតុគីមីឱ្យសមស្របក្នុងការរក្សាទុកក្នុងឃ្លាំង | | | |

| | | | | |
|---|---|---|---|---|
| ១៥ | ដាក់សារធាតុគីមីទៅតាមប្រភេទរបស់វា និងមានបិទស្លាកសញ្ញា និងឈ្មោះជាភាសាខ្មែរ និងភាសាឡាតាំង | | | |
| ១៦ | ដាក់សារធាតុគីមីដែលអាចមានប្រតិកម្មនឹងគ្នាដាច់ដោយឡែកពីគ្នា | | | |
| ១៧ | ទុកដាក់សារធាតុគីមីដាច់ដោយឡែកពីកន្លែងធ្វើការ និងអគារផលិតកម្ម | | | |
| ១៨ | ទុកដាក់ធុង ឬកំប៉ុងសារធាតុគីមីដែលប្រើរួចនៅទីកន្លែងដែលសមស្រប និងមានសុវត្ថិភាព | | | |
| ១៩ | មានការណែនាំអំពីនីតិវិធីដឹកជញ្ជូន សារធាតុគីមីដែលមានគ្រោះថ្នាក់បានត្រឹមត្រូវ | | | |
| ២០ | វេចខ្ចប់និងផ្ទុកសារធាតុគីមីដែលមានគ្រោះថ្នាក់ ដើម្បីដឹកជញ្ជូនបានសមស្របនិងមានសុវត្ថិភាព | | | |

| | | | | |
|---|---|---|---|---|
| ២១ | បណ្ដុះបណ្ដាលអ្នកដឹកជញ្ជូន ឱ្យមានសមត្ថភាពសមស្រប | | | |
| ២២ | មាននីតិវិធីគ្រប់គ្រងពេលអាសន្ន | | | |
| ២៣ | ទុកដាក់កាកសំណល់សារធាតុគីមីដែល គ្រោះថ្នាក់ដាច់ដោយឡែកពីកាកសំណល់ធម្មតា និងនៅឆ្ងាយពីកន្លែងធ្វើការ ឬអគារផលិតកម្ម | | | |
| **វិធានការការពារបុគ្គល** | | | | |
| ២៤ | វិភាគគោលការណ៍គ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ ដោយគិតគូលើវិធានការជំនួស ឬវិស្វកម្ម (ប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់) | | | |
| ២៥ | វាស់វែងគុណភាពខ្យល់នៅប៉ុស្តិ៍ការងារ ដោយវាយតម្លៃអំពីបរិមាណ ឬកំហាប់នៃសារធាតុគីមីដែលមាននៅក្នុងខ្យល់ | | | |

| | | | | |
|---|---|---|---|---|
| ២៦ | មានឧបករណ៍ ឬបរិក្ខារការពារបុគ្គលដែល សមស្រប តាមការកំណត់នៃច្បាប់ជាតិ ឬបទដ្ឋានជាតិ និងអន្តរជាតិ និងមានការបញ្ជាក់ទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច | | | |
| ២៧ | មានឧបករណ៍ ឬបរិក្ខារការពារផ្លូវដង្ហើម សមស្រប តាមការកំណត់នៃច្បាប់ជាតិ ឬបទដ្ឋានជាតិ និងអន្តរជាតិ និងមានការបញ្ជាក់ទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច | | | |
| ២៨ | មានសម្លៀកបំពាក់ការពារជាមួយសារធាតុគីមី និងផលិតគីមី សមស្រប | | | |
| ២៩ | រៀបចំបទបញ្ជាការងារសម្រាប់ការថែទាំ រក្សាទុក និងត្រួតពិនិត្យរាល់ឧបករណ៍ ឬបរិក្ខារការពារបុគ្គលដែលបានផ្តល់ដល់ កម្មករនិយោជិត ព្រមទាំងណែនាំដល់ពួកគេអំពីបទបញ្ជាការងារ | | | |

| | | | | |
|---|---|---|---|---|
| ៣០ | កម្មករនិយោជិត ប្រើ ឧបករណ៍ ឬបរិក្ខារការពារដែលបានផ្តល់បានត្រឹមត្រូវ | | | |
| ៣១ | សម្អាត សម្លាប់មេរោគ និងធ្វើតេស្តឡើងវិញនូវឧបករណ៍ការពារផ្លូវដង្ហើម លើកលែងតែឧបករណ៍ជំនួយដកដង្ហើមដែលអាចផ្លាស់ប្តូរបាន | | | |
| ៣២ | មានកន្លែងសម្រាប់បោកគក់ ការសម្អាត ការសម្លាប់មេរោគ និងការត្រួតពិនិត្យសម្លៀកបំពាក់ការពារ ឬឧបករណ៍ និងបរិក្ខារការពារបុគ្គលដែលបានប្រើប្រាស់ និងដែលប្រឡាក់សារធាតុគីមី | | | |
| ៣៣ | មានផែនការគ្រប់គ្រងឧបករណ៍ ឬបរិក្ខារការពារបុគ្គល ផ្លូវដង្ហើម និងសម្លៀកបំពាក់ការពារ ដោយធ្វើតេស្តភាពសមស្រប បណ្តុះបណ្តាល និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរ | | | |
| **ការឆ្លើយតបនៅគ្រាអាសន្ន** | | | | |

| | | | | |
|---|---|---|---|---|
| ៣៤ | មានវិធានការឆ្លើយតបនៅគ្រាអាសន្ន ដូចជា កណ្ដឹងរបៀបហៅរកជំនួយ ការប្រើប្រាស់ការពារ ការជម្លៀសខ្លួន... | | | |
| ៣៥ | មានវិធានការសង្គ្រោះបឋមនៅពេលៈ | | | |
| | សារធាតុគីមីចូលភ្នែក | | | |
| | សារធាតុគីមីជ្រាបចូលតាមស្បែក | | | |
| | លេបចូលតាមផ្លូវអាហារ | | | |
| | ស្រូបចូលតាមផ្លូវដង្ហើម | | | |
| **ការបណ្ដុះបណ្ដាល និងព័ត៌មាន** | | | | |
| ៣៦ | មានផែនការបណ្ដុះបណ្ដាលសម្រាប់គ្រប់កម្មករនិយោជិត | | | |
| ៣៧ | បណ្ដុះបណ្ដាលកម្មករនិយោជិតទៅតាមប្រភេទសារធាតុគីមី | | | |
| ៣៨ | មានផ្ដល់ព័ត៌មានទាក់ទងនិងសារធាតុគីមី.. | | | |
| **ការពិនិត្យតាមដាន និងវាយតម្លៃ** | | | | |

| | | | | |
|---|---|---|---|---|
| ៣៩ | មានបញ្ជីផ្ទៀងផ្ទាត់តាមដាន និងវាយតម្លៃការអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារធាតុគីមី | | | |

## ១២. ឯកសារយោង

១. អនុក្រឹត្យលេខ ១៨០អនក្រ/បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងដាក់ស្លាកសញ្ញាសារធាតុគីមី។

២. អនុសញ្ញាលេខ ១៧០របស់ អង្គការសុខភាពពិភពលោក ស្តីពីសុវត្ថិភាពនៃការប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅកន្លែងធ្វើការ។ ចាប់ផ្តើមពង្រឹងនៅថ្ងៃទី ០៤ ខែវិច្ឆិកាឆ្នាំ ១៩៩៣។

៣. គោលការណ៍ណែនាំ ស្តីពីសុខភាព និងសុវត្ថិភាពសម្រាប់ឧស្សាហកម្មលក់រាយ។ បោះពុម្ពផ្សាយនៅខែសីហា ឆ្នាំ២០១៣ ដោយ Asian Service Employees Trade Union Council, ASETUC.

៤. សុវត្ថិភាពក្នុងការប្រើប្រាស់សារធាតុគីមីនៅកន្លែងធ្វើការ (ILO)

៥. សៀវភៅមគ្គុទេសក៍សម្រាប់ការបណ្តុះបណ្តាលសុវត្ថិភាពសារធាតុគីមីនៅកន្លែងធ្វើការរបស់ ILO, WHO ក្រោមកិច្ចសហប្រតិបត្តិការជាមួយកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (United Nations Environment Programme)

៦. យោងអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

# ឧបសម្ព័ន្ធទី១ ៖រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ (Hazards Pictogram)



សារធាតុគីមីងាយឆេះ



អុកស៊ីតកម្ម (ងាយប្រតិកម្ម ជាមួយអុកស៊ីសែន)



សារធាតុគីមី កាត់ និងរលាកស្បែក



សារធាតុគីមី ពុល



សារធាតុគីមី ធ្វើឱ្យគ្រហាយ



សារធាតុគីមី ប៉ះពាល់បរិស្ថាន



សារធាតុគីមីងាយផ្ទុះ



បំពង់ឧស្ម័ន ដែលបំណែន



សារធាតុគីមី ធ្វើឱ្យប៉ះពាល់
សុខភាពមនុស្ស

បោះពុម្ពលើកទី ១ ឆ្នាំ ២០២២

ក្រោមជំនួយឧបត្ថម្ភ៖

International
Labour
Organization

ILO/Japan
Multi-bilateral
Programme